# សុន្ទរកថាស្វាគមន៍

## របស់បណ្ឌិត ជា ទុធណា អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង

## ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្នុងសិក្ខាសាលាស្តីពី

“**គោលការណ៍ណែនាំលើសវនកម្មបច្ចេកវិទ្យាព័ត៌មាន**”

សណ្ឋាគារភ្នំពេញ ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៩

រាជធានីភ្នំពេញ

- ខ្ញុំបាទ សូមសំដែងនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ចំពោះឯកឧត្តមបណ្ឌិត **ជូ គីមឡេង** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សូមគោរព លោកស្រី Sunniya Durrani- Jamal នាយកស្ថានតំណាងធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំកម្ពុជា
- សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា !

**១-** ថ្ងៃនេះ ពិតជាថ្ងៃដ៏រីករាយ ដែលយើងទាំងអស់គ្នា ជាសវនករផ្ទៃក្នុងនៃក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈរបស់រាជរដ្ឋាភិបាល បានមកចូលរួមក្នុងសិក្ខាសាលា ស្តីពី “**គោលការណ៍ណែនាំលើសវនកម្មបច្ចេកវិទ្យាព័ត៌មាន**” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ឯកឧត្តមបណ្ឌិត **ជូ គីមឡេង** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្នុងឋានៈជាអ្នកដឹកនាំ និងរៀបចំអង្គសិក្ខាសាលានេះ ខ្ញុំបាទសូមគោរពស្វាគមន៍ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះឯកឧត្តមបណ្ឌិត **ជូ គីមឡេង** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, លោកស្រី Sunniya Durrani- Jamal នាយកស្ថានតំណាងធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំកម្ពុជា ដែលបានចែករំលែកពេលវេលាដ៏មមាញឹកអញ្ជើញមកចូលរួមជាអធិបតី,

និងសូមស្វាគមន៍ដល់សវនករផ្ទៃក្នុង ព្រមទាំងភ្ញៀវកិត្តិយស សរុបចំនួន១៤៧ នាក់ ពីក្រសួង ស្ថាប័ន និង អង្គភាពសាធារណៈរបស់រាជរដ្ឋាភិបាលចំនួន៤៧ ដែលបានអញ្ជើញមកទទួលការបណ្តុះបណ្តាលនៅក្នុង សិក្ខាសាលារបស់យើងនាពេលនេះ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីគោរព រាប់អាន** !

**២-** យើងទាំងអស់គ្នាពិតជាទទួលស្គាល់ថា វិស័យបច្ចេកវិទ្យាព័ត៌មាន ជាវិស័យដែលមានការវិវត្តន៍លឿន និងមានឥទ្ធិពលយ៉ាងខ្លាំង មកលើសេដ្ឋកិច្ច សង្គម សិល្បៈ វប្បធម៌ សាសនា និងនយោបាយ និយាយរួម គឺ វិស័យនេះបាននិងកំពុងជ្រៀតចូលគ្រប់ទីកន្លែង គ្រប់ពេលវេលានៃដង្ហើមចេញចូលរបស់យើង។ បច្ចុប្បន្ន តាមមធ្យោបាយផ្សព្វផ្សាយនានា ជាតិ និងអន្តរជាតិ យើងតែងជួបប្រទះ និងឮ នូវសព្ទបច្ចេកទេសថ្មីប្លែកៗ ដូចជា: 4th Industrial Revolution, Digital Economy, Government Electronique, AI, Robotic, New Platform, Big Data, Block Chain...។ល។ និង។ល។ ដែលជាសព្ទតំណាងឱ្យរលកថ្មីនៃការវិវត្តន៍ គ្រឹះវិទ្យាសាស្ត្របច្ចេកវិទ្យាព័ត៌មាន ជាភាសានៃសម័យកុំព្យូទ័រជំនាន់ថ្មី ឆ្លុះបញ្ចាំងនូវប្រព័ន្ធបច្ចេកវិទ្យា ព័ត៌មានទំហំធំ ប្រទាក់ក្រឡា ស្មុគស្មាញ មានឥទ្ធិពលខ្លាំងនិងក្នុងទ្រង់ទ្រាយធំ ជាមួយល្បឿនកាន់តែលឿន កាន់តែគ្មានព្រំដែន និងកាន់តែអរូបិយ។ តើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលពួនខាងក្រោយឈ្មោះ និងសព្ទ បច្ចេកទេសថ្មីៗទាំងនេះ ត្រូវបានតាក់តែងយ៉ាងណា? មានទ្រង់ទ្រាយ រចនាសម្ព័ន្ធ និងដំណើរការទៅបែប ណា? នាំមកនូវកាលានុវត្តភាព និងហានិភ័យអ្វីខ្លះ? យើងទាំងអស់គ្នាប្រហែលជាពុំទាន់យល់ និងដឹងស៊ី ជម្រៅអស់នៅឡើយ។ ប្រការនេះទាមទារឱ្យសវនករផ្ទៃក្នុងត្រូវត្រៀមខ្លួនជាការប្រញាប់ និងឱ្យបានល្អ ដើម្បី រួមចំណែកដណ្តើមយកកាលានុវត្តភាព និងអត្ថប្រយោជន៍ពីវត្តមាននៃរលកថ្មីនេះ ជូនសង្គមជាតិ ដោយ ឡែក ជូនរាជរដ្ឋាភិបាលឱ្យដល់កម្រិតសក្តានុពល។

**៣-** ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានត្រូវបានផ្លាស់ប្តូរជាបន្តបន្ទាប់ តែអ្វីដែលមិនប្តូរ គឺគោលបំណង និងកម្មវត្ថុ របស់សវនកម្មផ្ទៃក្នុង ដែលនៅតែផ្តោតលើការពង្រឹងការតាក់តែង និងប្រតិបត្តិការនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង របស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងនោះ ដោយធានាឱ្យសម្រេចបាននូវគោលបំណងចំនួនបីចំបង ជូនអង្គ-ភាព គឺ: ១-ទទួលបានព័ត៌មានពេញលេញអាចជឿទុកចិត្តបាន ២-ប្រតិបត្តិការសម្រេចតាមគោលបំណង ដោយប្រសិទ្ធភាព និង៣-ធានាអនុលោមភាពតាមបទប្បញ្ញត្តិជាធរមាន។ ការទទួលខុសត្រូវនេះ បានកំណត់ ច្បាស់នៅក្នុងអនុក្រឹត្យលេខ៤០ អនក្រ.បកចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅនៃសវនកម្មផ្ទៃក្នុងនៅតាម ស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ មាត្រា៧ ស្តីពីមុខងារ និងការ ទទួលខុសត្រូវរបស់សវនកម្មផ្ទៃក្នុង ត្រង់ចំណុច៩ ដែលបានចែងថា "*... ធ្វើសវនកម្មលើប្រព័ន្ធកុំព្យូទ័រតាម កាវិយបរិច្ឆេទ និងធ្វើការវាយតម្លៃលើប្រព័ន្ធ ដំណើរការ ទិន្នន័យសំខាន់ៗក្រោយពេលតម្លើងរួច ដើម្បីកំណត់ ប្រព័ន្ធទាំងនេះឆ្លើយតបតាមគោលបំណងនិងគោលដៅដែលបានគ្រោងទុក ហើយទទួលបានលទ្ធផល មាន សុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់...*"។

**៤-** ដូច្នេះ ដើម្បីគាំទ្រដល់ការបំពេញភារកិច្ចនេះឱ្យសម្រេចជោគជ័យ ដោយធានាបាននូវគុណតម្លៃទាំងបី កសហវ បានចេញផ្សាយនូវក្របខ័ណ្ឌគ្រប់គ្រងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនៃបច្ចេកវិទ្យាព័ត៌មាន ដូចជា៖ "គោលនយោបាយ គោលការណ៍ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនៃប្រព័ន្ធ FMIS" នៅឆ្នាំ២០១៤ និង "ការគ្រប់គ្រងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងបច្ចេកវិទ្យាព័ត៌មាន" នៅឆ្នាំ២០១៦។ ទន្ទឹមនឹងនេះ កសហវ ក៏បានរៀបចំសិក្ខាសាលាពាក់ព័ន្ធមួយចំនួនរួចមកហើយដែរ ដូចជា÷ "សវនកម្មលើកម្មវិធីស្រេចបច្ចេកវិទ្យាព័ត៌មាន" ឆ្នាំ២០១៥, "ការគ្រប់គ្រងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងបច្ចេកវិទ្យាព័ត៌មាន" ឆ្នាំ២០១៧, "ក្រមសីលធម៌ វិជ្ជាជីវៈសវនកម្មផ្ទៃក្នុង និងបទពិសោធន៍សវនកម្មប្រព័ន្ធ FMIS" នៅឆ្នាំ២០១៨ ជាដើម។

**៥-** ទោះជាយ៉ាងនេះក្ដី ក៏របៀបរបប និងវិធីសាស្ត្រធ្វើសវនកម្មលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរួមមួយ ដែលមានលក្ខណៈច្បាស់លាស់ និងរៀបរយ នៅពុំទាន់បានកំណត់ ចងក្រង និងផ្សព្វផ្សាយនៅឡើយ។ ដូច្នេះ សិក្ខាសាលាស្ដីពី "**គោលការណ៍ណែនាំលើសវនកម្មបច្ចេកវិទ្យាព័ត៌មាន**" ថ្ងៃនេះ គឺជាជំហានថ្មីមួយទៀតដែលបានបោះទៅមុខចំពេលវេលា និងត្រូវទិសដៅ និងដែលយើងសង្ឃឹមថា នឹងចូលខ្លួនមកបំពេញបន្ថែមនូវចំណុចខ្វះខាត ពាក់ព័ន្ធនឹងគោលការណ៍ និងវិធីសាស្ត្រធ្វើសវនកម្មលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជាក់ជាមិនខាន។ ទន្ទឹមនឹងនេះ យើងទាំងអស់គ្នាក៏នឹងរង់ចាំទទួលយកនូវការណែនាំ និងអនុសាសន៍ល្អៗ ពីគណៈអធិបតី ដើម្បីជាប្រទីបឆ្លុះបំភ្លឺផ្លូវសម្រាប់ការអភិវឌ្ឍន៍មុខងារសវនកម្មផ្ទៃក្នុង ពិសេសផ្នែកសវនកម្មបច្ចេកវិទ្យាព័ត៌មាននៅក្នុងយុគសម័យឌីជីថលូបនីយកម្មនេះ។ សិក្ខាសាលារបស់យើងពិតជាមានរយៈពេលខ្លីមែន តែខ្ញុំសង្ឃឹមថាឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាជាសវនករផ្ទៃក្នុងទាំងអស់ នឹងខិតខំត្រងត្រាប់ទទួលយក និងរួមចំណែកផ្ដល់នូវធាតុចូលបន្ថែម ដើម្បីធានាឱ្យគោលការណ៍ណែនាំនេះ កាន់តែមានភាពពេញលេញ និងគ្រប់ជ្រុងជ្រោយ។

**អង្គសិក្ខាសាលា ជាទីមេត្រី** !

**៦-** មុខងារសវនកម្មផ្ទៃក្នុងបានធ្វើដំណើរ និងរីកធំធាត់មកដល់ពេលនេះ ក៏ដោយសារឆន្ទៈដ៏មោះមុតឥតងាករេរបស់រាជរដ្ឋាភិបាលកម្ពុជា ពិសេសរបស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងការជួយជ្រោមជ្រែងផ្នែកបច្ចេកទេស ពីសំណាក់ដៃគូអភិវឌ្ឍន៍នានា ក្នុងនោះជាចំបងគឺធនាគារអភិវឌ្ឍន៍អាស៊ី។ ធនាគារអភិវឌ្ឍន៍អាស៊ី អាចចាត់ទុកជាស្ថាបនិកមួយដ៏សំខាន់មួយ ដែលបានផ្ដល់នូវជំនួយបច្ចេកទេសជួយកសាងគ្រឹះបទដ្ឋានគតិយុត្ត និងមូលដ្ឋានបច្ចេកទេសសវនកម្មផ្ទៃក្នុង ចំនួន៣ លើករួចមកហើយ គឺលើកទី១ ចន្លោះឆ្នាំ២០០៤-២០០៥ បានជួយ

រៀបចំៈ អនុក្រឹត្យលេខ ៤០, សវនកម្មផ្ទៃក្នុង, ក្រមសីលធមិសម្រាប់វិជ្ជាជីវៈសវនកម្មផ្ទៃក្នុង និងគោលការណ៍គ្រប់គ្រងផ្ទៃក្នុង, លើកទី២ ឆ្នាំ ២០០៩-២០១១ បានជួយរៀបចំនីតិវិធីសវនកម្មផ្ទៃក្នុងលម្អិត ដែលក្លាយជាមូលដ្ឋាននៃសៀវភៅណែនាំសវនកម្មផ្ទៃក្នុង (បានបោះពុម្ពនិងចែកចាយរួចជូនក្រសួង ស្ថាប័ន) និងលើកទី៣ ឆ្នាំ២០១៩ បានផ្ដោតលើកការធ្វើសវនកម្មសមិទ្ធកម្ម និងបច្ចេកវិទ្យាព័ត៌មាន ដោយបានជួយរៀបចំគោលការណ៍ណែនាំសវនកម្មលើសមិទ្ធកម្ម និងលើបច្ចេកវិទ្យាព័ត៌មាន។ ដូច្នេះ ជាថ្មីម្ដងទៀត ខ្ញុំបាទសូមតំណាងឱ្យសវនករផ្ទៃក្នុងទាំងអស់ សំដែងនូវការអរគុណ និងដឹងគុណដ៏ជ្រាលជ្រៅជូនចំពោះរាជរដ្ឋាភិបាលកម្ពុជា, ចំពោះឯកឧត្ដមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារអភិវឌ្ឍន៍អាស៊ី ដែលមានលោកស្រី Sunniya Durrani- Jamal នាយកស្ថានតំណាងធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំកម្ពុជា បានអញ្ជើញចូលរួមជាកិត្តិយសនាពេលនេះផងដែរ។ ខ្ញុំក៏សូមកោតសរសើរ ព្រមទាំងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំអង្គភាពសវនកម្មផ្ទៃក្នុងទាំងអស់ ចំពោះការខិតខំបំពេញតួនាទីរបស់ខ្លួន និងសូមលើកទឹកចិត្តឱ្យបន្តពុះពារជម្នះរាល់ឧបសគ្គនានា ដើម្បីរួមចំណែកផ្ដល់សេវាសវនកម្មផ្ទៃក្នុងឱ្យបានជាឧត្ដមប្រយោជន៍ជូនអង្គភាពរបស់ខ្លួន។ ឆ្លៀតឱកាសនេះ ខ្ញុំក៏សូមអរគុណ និងផ្ដល់មូលវាចារណ៍ខ្ពស់ ជូនចំពោះមន្ត្រីរាជការនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានជួយគាំទ្រដល់សវនកម្មផ្ទៃក្នុងតាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈ បន្ថែមលើការងារប្រចាំថ្ងៃរបស់ខ្លួន និងជាពិសេសសម្រាប់ការរៀបចំសិក្ខាសាលាក្នុងថ្ងៃនេះ។ យើងទាំងអស់គ្នា ក៏មិនអាចបំភ្លេចនូវតួនាទីមិនអាចខ្វះបាន របស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលតែងតែជួយសម្របសម្រួលរាល់ការរៀបចំវគ្គបណ្ដុះបណ្ដាល និងសិក្ខាសាលាបានប្រកបដោយជោគជ័យ។

**៧-** យើងខ្ញុំជាសវនករផ្ទៃក្នុងទាំងអស់ សង្ឃឹមយ៉ាងមុតមាំថាសម្ដេច ឯកឧត្ដម លោកជំទាវជាថ្នាក់ដឹកនាំកំពូលនៃក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈ ព្រមទាំងដៃគូអភិវឌ្ឍន៍ ពិសេសធនាគារអភិវឌ្ឍន៍អាស៊ី នឹងបន្តជួយគាំទ្រ ព្រមទាំងជំរុញមុខងារនេះឱ្យបានរីកចម្រើនកាន់តែខ្លាំងក្លាថែមទៀត។

**៨-** ជាទីបញ្ចប់ ខ្ញុំសូមគោរពជូនពរ **ឯកឧត្ដម លោកជំទាវ លោក លោកស្រី នាងកញ្ញា** សូមមានសុខភាពល្អបរិបូណ៌ និងសមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ។